ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខៈ ២៥ ប្រ.ក

[illegible]
ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១២

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្ម សេវាកម្មចាក់បញ្ចាំងស្លាដែភាពយន្ត និងស្លាដែវីដេអូ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

-បានឃើញអនុក្រឹត្យលេខ២៨អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យភាពយន្ត និងវីដេអូ

-យោងសារាចរណែនាំលេខ០៧ សរណ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ ស្តីពីការអនុវត្តអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅគ្រប់គ្រងលើអាជីវកម្ម សេវាកម្ម ចាក់បញ្ចាំងស្លាដែភាពយន្ត និងស្លាដែវីដេអូ ក្នុងគោលបំណងធានាឲ្យមានការគោរពសិទ្ធិ ការការពារស្លាដែភាពយន្តវីដេអូ ដើម្បីរួមចំណែកលើកស្ទួយវប្បធម៌ជាតិ សណ្តាប់ធ្នាប់សាធារណៈ ការគោរពសីលធម៌សង្គម និងការប្រកបអាជីវកម្ម

សេវាកម្មស្របច្បាប់លើផលិតផលវប្បធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ២.-**

អាជីវកម្ម សេវាកម្មបញ្ចាំងស្នាដៃភាពយន្ត និងស្នាដៃវីដេអូ សំដៅលើការចាក់បញ្ចាំងផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយដែលត្រូវបានកំណត់ក្នុងប្រកាសនេះ មានដូចខាងក្រោម៖

ក-រោងបញ្ចាំង ដែលមានចំនួនកៅអី ក្រោម ២០០(ពីររយ)កន្លែង

ខ-សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ហាងកាហ្វេ បៀរហ្គាដិន រង្គសាល ក្លិបកំសាន្ត មជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលមានបញ្ចាំងស្នាដៃភាពយន្តនិងស្នាដៃវីដេអូ

គ-ភាពយន្ត វីដេអូចល័ត ។

**ប្រការ៣.-**

ការប្រកបអាជីវកម្ម សេវាកម្មដូចមានចែងក្នុងប្រការ២ ត្រូវមានការអនុញ្ញាតពីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ រាជធានី ខេត្ត ឬការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌគោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

រាល់ការអនុញ្ញាត ត្រូវមានកម្រៃសេវាកម្ម ដែលកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ តាមតារាងកម្រៃសេវាកម្មរបស់ការិយាល័យច្រកចេញចូលតែមួយ នៃក្រុង ស្រុក ខណ្ឌគោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ៤.-**

ហាមយកស្នាដៃភាពយន្ត និងស្នាដៃវីដេអូ គ្មានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ទៅចាក់បញ្ចាំងផ្សព្វផ្សាយជាសាធារណៈ ។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានសិល្បៈភាពយន្ត និង ផ្សព្វផ្សាយវប្បធម៌ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ១ ឆ្នាំ ២០១២

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

**កន្លែងទទួលៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងស្ថាប័ន

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់សាលារាជធានី ខេត្ត

" ដើម្បីសហការ"

-ដូចប្រការ៥

-រាជកិច្ច

-ឯកសារ- កាលប្បវត្តិ